01067644

002/19-09-2007-ECCC/TC
**E1/258**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2015
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**
**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ សុក្រ ទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

**សវនាការលើអង្គសេចក្តី - ថ្ងៃ ២៣៩**

រៀបចំដោយ៖ **ជា ស៊ីវហ៉ង** និង **Roger PHILLIPS**

| **<u>កំណត់ហេតុអ្នកចូលរួម</u>** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក Roger PHILLIPS, កញ្ញា ជា ស៊ីវហ៉ង |
| ការិយាល័យសហព្រះរាជអាជ្ញា៖លោក សេង ប៊ុនឃាង, កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK, លោក Vincent de WILDE D'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ កញ្ញា ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, កញ្ញា ម៉ុច សុវណ្ណារី, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី Martine JACQUIN, លោក Mahesh RAI |

| |
|---|
| សាក្សី/ដើមបណ្តឹង ៖ សយ សែន (2-TCCP-271) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, កញ្ញា សំ មករា; លោក មៀច សុវណ្ណា; កញ្ញា សុក សុភ័គមណីកា, កញ្ញា តួច គន់នារី |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១៥.៣០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤៤ | បញ្ចប់ម៉ោង៖ ១១.០៤ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៥២ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៣០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៦ |
| ការស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់ជនជាប់ចោទ នួន ជា | មេធាវីការពារក្តី នួន ជា | ០៩.០៦ | ០៩.០៩ |
| ការតាំងសំណួរទៅកាន់សាក្សី សយ សែន (2-TCCP-271) | មេធាវីការពារក្តី នួនជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៩<br>១៣.៥២ | ១១.៣៣<br>១៥.២៨ |
| ការកត់សម្គាល់ពីព័ត៌មានឯកជនរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើផ្លូវភេទ | មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ០៩.២៦<br>០៩.៣៣ | ០៩.២៧<br>០៩.៣៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន លោក Arthur VERCKEN និងសហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ។ ជនជាប់ចោទ នួន ជា មានវត្តមាន នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**ការស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់ នួន ជា**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ក្នុងការលះបង់សិទ្ធចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271)**

មេធាវីការពារក្តី នួន ជា បន្តការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-271)។ បន្ទាប់មកក្រុមមេធាវីការពារក្តីលោក ខៀវ សំផន តាំងសំណួរ។

**ការកត់សម្គាល់ពីព័ត៌មានឯកជនរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើផ្លូវភេទ**

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងពីបញ្ហាពាក់ព័ន្ធនឹងព័ត៌ឯកជនរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើផ្លូវភេទ ដែលត្រូវពិភាក្សាក្នុងសវនាការជាសាធារណៈ។ អង្គជំនុំជម្រះណែនាំដល់ភាគី ដែលមានបំណងក្នុងការចោទជាសំនួរពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ជនរងគ្រោះដោយសារអំពើហិង្សាលើផ្លូវភេទ ដោយឲ្យភាគីសរសេរឈ្មោះអ្នកទាំងនោះនៅលើក្រដាសដើម្បីកំណត់អត្តសញ្ញាណ ហើយប្រសិនបើការធ្វើដូច្នេះចោទជាសំនួរបន្ថែម អង្គជំនុំជម្រះនឹងពិចារណាក្នុងការធ្វើសវនាការជាអសាធារណៈ។

## កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង

| លេខ E3 | លេខ កសចស | ERN (KH, ENG, FR) | ចំណងជើងឯកសារ | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|---|
| E3/4846 | | 00527717-00527770 00527771-00527796 00943267-00943276 | DC-CAM Document "Interview with Soy Sen" | P | 00527724 00527744 | 00527774 00527775 00527785 | 00943272 00943274 00943275 |
| E3/5214 | | 00223055-00223070 00225500-00225513 00702886-00702902 | [Corrected 1] Written Record of Interview of SÂY Sen | P | | 00225505 | 00702891 |
| E3/5522 | | 00414481-00414491 00426280-00426290 00436899-00436910 | Written Record of Interview of [Redacted], dated 08 December 2009 | C | 00414488 00414489 | 00426286 00426287 | 00436906 00436907 |
| E3/2062 | | 00079436-00079442 00301363-00301370 00789274-00789282 | Brief history of "Genocidal Site" Kraing Ta Chan of Pol Pot-Ieng Sary Clique, Kus sub-district, Tram Kak district, Takeo province | P | 00679441 00679442 | 00301369 | 00789280 |
| E3/5827 | D 157.7 | 00270855-00270897 00866424-00866463 00872799-00872835 | [Partial.T] Victim's background | P | | 00866461 | 00872833 00872834 |
| E3/5828 | D125/220 | 00365707-00365713 00363337-00363340 00371249-00371253 | Report of the Execution of Rogatory Letter, dated 17-03-2009: Site Identification Report | P | | 00363337 | |
| E3/5829 | D125/220.36 | 00365691-00365691 00363332-00363332 00371258-00371258 | Annex C: Fig1 GPS track showing the route to Kraing Ta Chān Security Centre and Fig 2 Indication of the position of Kraing Ta Chān (KTC) Security Centre | P | 00365691 | 00363332 | 00371258 |
| E3/5830 | D125/220.37 | 00365692-00365692 | Annex D: Plan of Kraing Ta Chān Security Centre | P | 00365692 | 00363333 | 00371259 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00363333-00363333 00371259-00371259 | compiled from information provided by witness SÂY Sèn | | | | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការនៅក្រោមសាលសវនាការ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ មកសាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឲ្យបានមុនម៉ោង ០៩ ព្រឹក។

<u>កាលវេលាសវនាការបន្ត</u>

សវនាការនឹងបន្តទៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីវប... ...ger PHILLIPS**